៨/៥-៥

នាយកដ្ឋាន សិលាចារឹក
ចូល លេខ ០២
ថ្ងៃទី ០១ ... ០១
បញ្ជូនទៅ...

នស/រកម/០២១១/០០៥

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៣/០០១/២០១១ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :



ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# សមាជរដ្ឋសភានិងព្រឹទ្ធសភា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ស្របតាមមាត្រា ១១៦ថ្មី និងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

សមាជរដ្ឋសភានិងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នានៃសមាជិករដ្ឋសភានិងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិក្នុងករណីចាំបាច់ ។

បន្ទាប់ទៅនេះ សមាជរដ្ឋសភានិងព្រឹទ្ធសភា ត្រូវកំណត់ហៅថា សមាជ ។

**មាត្រា ៣.-**

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិមាន :

- ការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់ឯករាជ្យ អធិបតេយ្យ និង បូរណភាពទឹកដី ឬ
- ករណីប្រធានសក្តិ បណ្តាលឲ្យមានវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ជាតិ និងប្រជាជន ឬ
- ករណីផ្សេងៗទៀត ដែលគណៈកម្មាធិការសមាជយល់ឃើញថា ជាបញ្ហាសំខាន់របស់ប្រទេសជាតិ ។

## ជំពូកទី ២
## ការរៀបចំសមាជ

**មាត្រា ៤.-**

ប្រធានព្រឹទ្ធសភា ជាប្រធានសមាជ ។

ក្នុងករណីប្រធានសមាជអវត្តមាន ឬ មានធុរៈមិនអាចបំពេញមុខងារបាន ប្រធានរដ្ឋសភាត្រូវទទួលភារកិច្ចជំនួស ។

តំណែងជំនួសប្រធានសមាជ ដូចមានចែងខាងលើនេះ អាចនឹងផ្ទេរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ:

- អនុប្រធានទី១ ព្រឹទ្ធសភា
- អនុប្រធានទី១ រដ្ឋសភា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Ksl

- អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី២ រដ្ឋសភា ។

**មាត្រា ៥.-**

សមាជ ត្រូវធ្វើជាសាធារណៈ នៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

**មាត្រា ៦.-**

សមាជ មានគណៈកម្មាធិការសមាជមួយជាអ្នករៀបចំសមាជ ។

សមាសភាពគណៈកម្មាធិការសមាជមានដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២- ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣- អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |
| ៤- អនុប្រធានទី១ រដ្ឋសភា | សមាជិក |
| ៥- អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦- អនុប្រធានទី២ រដ្ឋសភា | សមាជិក ។ |

ប្រធានគណៈកម្មការទាំងអស់នៃព្រឹទ្ធសភានិងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**មាត្រា ៧.-**

ប្រធានសមាជមានមុខងារដូចតទៅ:

ក- ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវ តាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន

ខ- ដឹកនាំអង្គប្រជុំនៃសមាជ

គ- បើក និង លើកពេលប្រជុំនៃសមាជ

ឃ- ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំសមាជ

ង- ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជ

ច- រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ

ឆ- ជាតំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។

**មាត្រា ៩.-**

រាល់ការចំណាយសម្រាប់ដំណើរការសមាជ ជាបន្ទុករបស់រដ្ឋសភា ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃសមាជ

**មាត្រា ១០.-**

ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី អាចផ្តួចផ្តើមឲ្យមានការប្រជុំសមាជបាន ។

ប្រធានសមាជ អញ្ជើញសមាជិករដ្ឋសភា និងព្រឹទ្ធសភាឲ្យចូលរួមប្រជុំសមាជ ។

**មាត្រា ១១.-**

ការប្រជុំសមាជនឹងយកជាការបាន លុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

**មាត្រា ១៣.-**

សេចក្តីសម្រេចរបស់សមាជ មានតម្លៃជាសេចក្តីសម្រេចខ្ពស់បំផុតរបស់ប្រជាជាតិ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ និងចុះក្នុងរាជកិច្ច ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

សមាជប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរ ក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បីពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាតនៃ

ចំនួនសមាជិករដ្ឋសភាទាំងមូល និងដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងដំណើរការនៃកិច្ចប្រជុំសមាជលើកដំបូងនេះ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវយកមកអនុវត្តរហូតដល់សមាជអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនបាន ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរល.០២១១.០៧៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខៈ ១៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនអេន

សេចក្តីស្នើ

១

២០ មេសា ១

# បទបញ្ជាផ្ទៃក្នុង
# នៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

បទបញ្ជាផ្ទៃក្នុងនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ព្រមទាំងនីតិវិធីទាំងឡាយដែលត្រូវប្រើក្នុងសមាជ ។

**ប្រការ ២.-**

សមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវស្ថិតនៅក្រោមអធិបតីភាពនៃប្រធានព្រឹទ្ធសភា។

សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា ជាសមាជិកនៃអង្គសមាជ។

## ជំពូកទី ២
## អំពី ប្រធាន អនុប្រធាន និងគណៈកម្មាធិការសមាជ

**ប្រការ ៣.-**

សមាសភាពគណៈកម្មាធិការសមាជមានដូចតទៅ ៖

| | |
|---|---|
| ១-ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២-ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣-អនុប្រធានទី១ ព្រឹទ្ធសភា | សមាជិក |
| ៤-អនុប្រធានទី១ រដ្ឋសភា | សមាជិក |
| ៥-អនុប្រធានទី២ ព្រឹទ្ធសភា | សមាជិក |
| ៦-អនុប្រធានទី២ រដ្ឋសភា | សមាជិក ។ |

ប្រធានគណៈកម្មការទាំងអស់នៃព្រឹទ្ធសភា និងរដ្ឋសភា ជាជំនួយការគណៈកម្មាធិការសមាជ ។

**ប្រការ ៤.-**

ប្រធានសមាជមានមុខងារដូចតទៅ ៖

ក-ធានាការប្រព្រឹត្តទៅនៃសមាជឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

ខ-ដឹកនាំអង្គប្រជុំសមាជ និងគណៈកម្មាធិការសមាជ ។

គ-បើក និងលើកពេលប្រជុំសមាជ។

ឃ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំ និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងការសម្រេចរបស់សមាជ ។

ង-ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ។

ច-រក្សាការពារសណ្តាប់ធ្នាប់ក្នុងពេលប្រជុំសមាជ ។

ឆ-តំណាងសមាជក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ។

**ប្រការ ៥.-**

អនុប្រធានសមាជ ជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន ។ ក្នុងករណីប្រធានសមាជអវត្តមាន ឬមានធុរៈមិនអាចបំពេញមុខងារបាន អនុប្រធានធ្វើការជួសប្រធានក្នុងឋានៈជាប្រធានស្តីទី តាមលិខិតផ្ទេរសិទ្ធិ ។

តំណែងជំនួសប្រធានសមាជ អាចនឹងដូរទៅឥស្សរជនផ្សេងៗ តាមឋានានុក្រមដូចតទៅ ៖

១-អនុប្រធានទី១ ព្រឹទ្ធសភា

២-អនុប្រធានទី១ រដ្ឋសភា

៣-អនុប្រធានទី២ ព្រឹទ្ធសភា

៤-អនុប្រធានទី២ រដ្ឋសភា។

**ប្រការ ៦.-**

គណៈកម្មាធិការសមាជ ទទួលពិនិត្យ និងសម្រេចបញ្ហាសំខាន់របស់ប្រទេសជាតិ ដែលត្រូវដាក់ជារបៀបវារៈរបស់អង្គប្រជុំសមាជ ។

## ជំពូកទី ៣
## អំពី អគ្គលេខាធិការដ្ឋានសមាជ

**ប្រការ ៧.-**

អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលបន្ទុកជាអគ្គលេខាធិការដ្ឋានសមាជ ។

អគ្គលេខាធិការដ្ឋានសមាជ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់គណៈ-កម្មាធិការសមាជ ទទួលបន្ទុកកិច្ចការរដ្ឋបាល សន្តិសុខ ហិរញ្ញវត្ថុ និងសេវាទាំងឡាយរបស់សមាជ ។

ភារកិច្ចសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានសមាជមាន៖

ក-ធ្វើគម្រោងថវិកា បែបបទនៃចំណូល និងចំណាយថវិកា និងរបាយការណ៍ទូទាត់ ចំណូល ចំណាយថវិការបស់សមាជ ។

ខ-ធ្វើកំណត់ហេតុប្រជុំសមាជ និងប្រជុំគណៈកម្មាធិការសមាជ ។

គ-ផ្តល់គ្រប់កំណត់ហេតុ ឬសេវាខាងនីតិវិធី ច្បាប់ ជំនាញ និងបច្ចេកទេសជូនគណៈកម្មាធិការសមាជ និងសមាជិកសមាជ ។

ឃ-រក្សាកំណត់ហេតុ និងឯកសារទាំងអស់របស់សមាជ មិនឲ្យបែកខ្ញែកខ្ចាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតពីប្រធានសមាជឡើយ ។

**ប្រការ ៨..**

អគ្គលេខាធិការដ្ឋានសមាជ ត្រូវដឹកនាំដោយអគ្គលេខាធិការរដ្ឋសភា និងអមដោយអគ្គលេខាធិការរងតាមការចាំបាច់ ។

## ជំពូកទី ៤
## អំពី របៀបវារៈ

**ប្រការ ៩..**

គណៈកម្មាធិការសមាជ ជាអ្នករៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំសមាជ ។

**ប្រការ ១០..**

របៀបវារៈអង្គប្រជុំសមាជមានសេចក្តីជាលំដាប់មុនក្រោយដូចតទៅនេះ៖

-លិខិតផ្តួចផ្តើមរបស់ឥស្សរជនជាន់ខ្ពស់ដូចមានបញ្ញត្តក្នុងកថាខ័ណ្ឌទី១ មាត្រា១០ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

-បញ្ហាសំខាន់ៗ ដែលគណៈកម្មាធិការសមាជ បានសម្រេចរៀបក្នុងរបៀបវារៈ ។

## ជំពូកទី៥
## អំពីរបៀបប្រជុំសមាជ

**ប្រការ ១១.-**

អាសនានុក្រមនៃសមាជិកសមាជ ត្រូវរៀបជាក្រុមៗ តាមគណបក្សនយោបាយពីមុខទៅក្រោយ ។ ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិចដប់ប្រាំរូប ។ សមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្រមួយរូបអាចចូលជាសមាជិករបស់ក្រុមតែមួយប៉ុណ្ណោះ ។ ក្រុមនីមួយៗត្រូវមាន ប្រធានមួយរូប អនុប្រធានមួយរូប ។ គណបក្សនយោបាយណាមានអាសនៈតិច ជាងដប់ប្រាំត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ ។

បញ្ជីរាយនាមរបស់ក្រុមសមាជិកសមាជ នៃគណបក្សនយោបាយ ត្រូវផ្ញើជូនប្រធានសមាជ ។

**ប្រការ ១២.-**

ការកំណត់ថ្ងៃប្រជុំ ត្រូវធ្វើជាលិខិតផ្ញើជូនសមាជិកសមាជ ។

សមាជ ត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជាក្នុងសាលប្រជុំរដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

**ប្រការ ១៣.-**

លិខិតអញ្ជើញ ត្រូវមានភ្ជាប់ជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងករណីប្រញាប់ ។

**ប្រការ ១៤ .-**

ក្នុងពេលប្រជុំសមាជនីមួយៗ លេខាធិការស្រង់ឈ្មោះសមាជិកសមាជដែលអវត្តមាន ។ ឈ្មោះសមាជិកដែលអវត្តមានគ្មានច្បាប់អនុញ្ញាត ត្រូវប្រកាសក្នុងអង្គប្រជុំ ។

**ប្រការ ១៥.-**

ការប្រជុំសមាជ នឹងយកជាការបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល និងលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) នាទី ក្រោយពេលកំណត់ចាប់ផ្ដើមការប្រជុំ ប្រធានសមាជ ត្រូវលើកពេលប្រជុំ ។

**ប្រការ ១៦.-**

សមាជ ត្រូវប្រជុំជាសាធារណៈ។ កំណត់ហេតុនៃការប្រជុំសមាជ មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្ដារ។ កំណត់ហេតុទាំងអស់ ត្រូវតម្កល់ទុកក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា។

សមាជ អាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីព្រះមហាក្សត្រ ពីប្រធានព្រឹទ្ធសភា ពីប្រធានរដ្ឋសភា ឬពីនាយករដ្ឋមន្ត្រី ។

**ប្រការ ១៧.-**

បើមានបញ្ហាអ្វីនឹងថ្លែងជំរាបអង្គសមាជនោះ ប្រធានអាចថ្លែងមុននឹងចាប់ ធ្វើការតាមរបៀបវារៈ ។

**ប្រការ ១៨.-**

មុននឹងចាប់ផ្ដើមកិច្ចប្រជុំនីមួយៗ សមាជអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការអង្គប្រជុំចំនួនបួនរូប ដែលពីររូបជាសមាជិករដ្ឋសភា និងពីររូបជាសមាជិកព្រឹទ្ធសភា ។

**ប្រការ ១៩.-**

លេខាធិការអង្គប្រជុំសមាជ ជួយប្រធានសមាជលើកិច្ចការដូចតទៅ៖

-ពិនិត្យកូរ៉ុមសម្រាប់ប្រជុំ និងនៅពេលអនុម័ត

-កត់ឈ្មោះសមាជិកសមាជ ដែលសុំបញ្ចេញយោបល់តាមលំដាប់មុនក្រោយ

-រៀបចំការបោះឆ្នោតចំហ ឬសម្ងាត់

-បំពេញកិច្ចការផ្សេងទៀត តាមមសេចក្ដីណែនាំរបស់ប្រធានសមាជ ។

**ប្រការ ២០.-**

ក្នុងការជជែកពិភាក្សា វាគ្មិនត្រូវនិយាយឆ្លាស់គ្នា អ្នកគាំទ្រនិយាយម្ដងរួចអ្នកជំទាស់និយាយម្ដង ។

**ប្រការ ២១..**

តាមគោលការណ៍ រយៈពេលនិយាយសម្រាប់សមាជិកសមាជ ត្រូវមានកំណត់ ហើយត្រូវនិយាយតែពីប្រធានបទដែលកំពុងពិភាក្សា ។ បើនិយាយក្រៅប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះវិញ ។ បើសមាជិកសមាជនោះ នៅចចេសនិយាយក្រៅប្រធានបទដដែល ប្រធានអង្គប្រជុំអាចបញ្ឈប់វាគ្មិននោះកុំឲ្យនិយាយបន្តទៅទៀត ។

**ប្រការ ២២..**

សមាជិកសមាជដែលបានចុះឈ្មោះសុំបញ្ចេញយោបល់ និយាយបានដប់នាទីយ៉ាងយូរ។ សមាជិកដែលគ្រាន់តែឆ្លើយតបនិយាយបានត្រឹមតែប្រាំនាទី។ បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សាអាចអនុញ្ញាតបន្ថែមប្រាំនាទី។ ការបន្ថែមនេះ អាចអនុញ្ញាតឲ្យបន្តបានពីរដងក្នុងប្រធានបទតែមួយ។

**ប្រការ ២៣..**

បទប្បញ្ញត្តិអំពីការចុះឈ្មោះសុំនិយាយជាលំដាប់គ្នា និងអំពីកំណត់រយៈពេលនិយាយនេះ ប្រើសម្រាប់តែសមាជិកសមាជមិនប្រើសម្រាប់ម្ចាស់សំណើទេ។

**ប្រការ ២៤..**

ហាមមិនឲ្យនិយាយកាត់ពាក្យអ្នកដទៃ មិនឲ្យនិយាយវាយប្រហារលើបុគ្គល មិនឲ្យសម្តែងអាការៈផ្សេងៗ ដែលនាំឲ្យខូចសណ្តាប់ធ្នាប់ ។

## ជំពូកទី ៦
## អំពី ការរក្សាសេចក្តីស្ងប់ស្ងាត់ក្នុងពេលប្រជុំ

**ប្រការ ២៥ ..**

ប្រធានសមាជមានភារៈរក្សាការពារ មិនឲ្យមានភាពជ្រួលច្របល់ និងភយន្តរាយខាងក្នុងក្តី មកពីខាងក្រៅក្តីដែលកើតមានឡើងដល់សមាជ ។ ដើម្បីធ្វើឲ្យសម្រេចកិច្ចនេះ ប្រធានអាចសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងទ័ព ។

## ជំពូកទី ៧
## អំពី ការខានមកប្រជុំ

**ប្រការ ២៦..**

សមាជិកសមាជមិនអាចអវត្តមាន ដោយមិនមានការអនុញ្ញាតពីប្រធានសមាជបានឡើយ។

ក្នុងករណីបន្ទាន់ ត្រូវជូនដំណឹងមកប្រធានសមាជ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ។

## ជំពូកទី ៨
## អំពី ការបញ្ចេញមតិ

**ប្រការ ២៧ ..**

ក្នុងបញ្ហាសំខាន់ៗទាំងឡាយដែលសមាជត្រូវពិនិត្យ សមាជបញ្ចេញមតិដោយវិធីបីយ៉ាង គឺដោយលើកដៃ ដោយបោះឆ្នោតចំហ ឬបោះឆ្នោតសម្ងាត់។

វិធីបញ្ចេញមតិដោយលើកដៃ ឬដោយបោះឆ្នោតចំហខាងលើនេះអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច។

**ប្រការ ២៨..**

នីតិវិធីនៃការបោះឆ្នោតបញ្ចេញមតិ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ប្រការ៣៧ ប្រការ៣៨ថ្មី និងប្រការ៣៩ ត្រូវយកមកប្រើសម្រាប់ការបោះឆ្នោតបញ្ចេញមតិនៅក្នុងអង្គសមាជផងដែរ។

ការបោះឆ្នោតសម្ងាត់ ត្រូវកំណត់ដោយគណៈកម្មាធិការសមាជ។

**ប្រការ ២៩..**

ការអនុម័តរបស់សមាជ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

ក្រោយបានលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានសមាជ ត្រូវប្រកាសថាសមាជបានអនុម័តយល់ព្រមហើយ ឬថាសមាជបានអនុម័តមិនយល់ព្រមទេ ។

## ជំពូកទី ៩
## អំពី វិន័យ

**ប្រការ ៣០..**

ទណ្ឌកម្មខាងវិន័យ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ប្រការ៧៣ ប្រការ៧៤ ប្រការ៧៥ និងប្រការ៧៩ ត្រូវយកមកអនុវត្តចំពោះសមាជិកសមាជផងដែរ ។

## ជំពូកទី ១០
## អំពី ការកែប្រែបទបញ្ជាផ្ទៃក្នុង

**ប្រការ ៣១..**

បទបញ្ជាផ្ទៃក្នុងនេះនឹងកែប្រែបាន លុះត្រាតែមានសេចក្តីស្នើសុំពីសមាជិកមួយភាគបួនយ៉ាងតិចនៃចំនួនសមាជិកសមាជទាំងមូល ហើយត្រូវអនុម័តយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកសមាជទាំងមូល ។

បទបញ្ជាផ្ទៃក្នុងនេះត្រូវបានអង្គសមាជរដ្ឋសភា និងព្រឹទ្ធសភា
អនុម័តនៅថ្ងៃទី........ខែ.........ឆ្នាំ២០១១
នាសម័យប្រជុំសមាជលើកដំបូង ។
រាជធានីភ្នំពេញ,ថ្ងៃទី.........ខែ.........ឆ្នាំ២០១១

**ប្រធានសមាជ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា
ចូល
លេខ......៣១៣១
ថ្ងៃទី......ខែ......ឆ្នាំ២០១០ ម៉ោង......
បញ្ជូនទៅ......

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីស្នើច្បាប់
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

អនុលោមតាមមាត្រា ១១៦ ថ្មី និងមាត្រា ១១៧ ថ្មី ជំពូកទី ៩ ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងយោងទៅលើបទពិសោធន៍ជាវិជ្ជមានរបស់ប្រទេសមួយចំនួន ដែលអនុវត្តប្រព័ន្ធសភាពីរ សមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា បានព្រមព្រៀងមូលមតិគ្នារៀបចំសេចក្តីស្នើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភានេះឡើង ។

សមាជរដ្ឋសភា និងព្រឹទ្ធសភា គឺជាការប្រជុំរួមគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ក្នុងកាលៈទេសៈដែលមានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងក្នុងពេលដែលប្រទេសជាតិទទួលរងនូវវិនាសកម្ម ឬប្រឈមនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរ ដែលចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ ។ ការប្រជុំរួមគ្នាជាសមាជ អាចដំណើរការបាន ចាំបាច់ត្រូវមានច្បាប់ ដែលជាឧបករណ៍គតិយុត្ត សម្រាប់កំណត់អំពីយន្តការ នីតិវិធី និងវិធានផ្សេងៗ ដើម្បីជានាដល់កិច្ចដំណើរការ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គសមាជនេះ ។

ការបង្កើតច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា គឺជាការលើកកម្ពស់ឧត្តមភាព និងប្រសិទ្ធភាពការងាររបស់ស្ថាប័ននីតិបញ្ញត្តិ ឲ្យមានការទទួលខុសត្រូវកាន់តែខ្ពស់ថែមទៀត ក្នុងការបម្រើប្រទេសជាតិ និងប្រជាជន តាមរយៈការឆ្លើយតបនិងដោះស្រាយបានទាន់ពេលវេលានូវបញ្ហាសំខាន់ៗជាបន្ទាន់របស់ប្រទេសជាតិ ។

សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវបានតាក់តែងឡើង មាន ៤ ជំពូក ចែកជា ១៤ មាត្រា ដែលមានអត្ថន័យជាសារវន្ត ដូចខាងក្រោម ៖

- ជំពូកទី ១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា ពីមាត្រា ១ ដល់មាត្រា ៣ ចែងកំណត់អំពីគោលដៅ គោលបំណង និងវិសាលភាព ។

- ជំពូកទី ២ ស្តីពីការរៀបចំសមាជ មាន ៦ មាត្រា ពីមាត្រា ៤ ដល់មាត្រា ៩ ចែងកំណត់អំពីប្រធានសមាជ ទីកន្លែងប្រារព្ធធ្វើសមាជ គណៈកម្មាធិការសមាជ មុខងារប្រធានសមាជ អគ្គលេខាធិការដ្ឋានសមាជ និងបន្ទុកចំណាយសម្រាប់ដំណើរការសមាជ ។

- ជំពូកទី ៣ ស្តីពីការប្រព្រឹត្តទៅនៃសមាជ មាន ៤ មាត្រា ពីមាត្រា ១០ ដល់មាត្រា ១៣ ចែងកំណត់អំពីឥស្សរជនដែលមានសមត្ថកិច្ចផ្តួចផ្តើមឲ្យមានប្រជុំសមាជ ការកោះអញ្ជើញឲ្យចូលរួមប្រជុំសមាជ កូរ៉ុមប្រជុំ សំឡេងអនុម័ត និងវិសាលភាពនៃសេចក្តីសម្រេចរបស់សមាជ ។

- ជំពូកទី ៤ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ១៤ ចែងកំណត់អំពីរយៈពេល ព្រមទាំងរបៀបវារៈដែលសមាជត្រូវដំណើរការប្រជុំដំបូងរបស់ខ្លួន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តលើសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា តាមការគួរ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០

តំណាងក្រុមសមាជិកព្រឹទ្ធសភា រដ្ឋសភាហត្ថលេខីនៃសេចក្តីស្នើច្បាប់

**គង់ សារាជ** **ស៊ិក ប៊ុនហុក**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានសេវាច្បាប់ និងសមុហភាពដែនដី
នាយកដ្ឋានស្រាវជ្រាវច្បាប់

# របាយការណ៍

## តាមដានការប្រជុំពេញអង្គនៃរដ្ឋសភាលើសេចក្តីស្នើច្បាប់
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

### I-និដ្ឋភាពទូទៅ

#### ១-ប្រភពនៃសេចក្តីស្នើច្បាប់

យោងទៅលើបទពិសោធន៍ជាវិជ្ជមានរបស់ប្រទេសមួយចំនួន ដែលអនុវត្តប្រព័ន្ធសភាពីរ និងដើម្បីធ្វើឱ្យស្រប ជាមួយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាផងនោះ សមាជិកព្រឹទ្ធសភា និងអ្នកតំណាងរាស្ត្របានព្រមព្រៀងមូលមតិគ្នា រៀបចំសេចក្តីស្នើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភានេះឡើង ។

#### ២-ទម្រង់នៃសេចក្តីព្រាងច្បាប់

សេចក្តីស្នើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មាន៤ជំពូក និងចែកចេញជា១៤មាត្រា ដែលមានអត្ថន័យដូចខាងក្រោម :

ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន៣មាត្រា ហើយពីមាត្រា១ ដល់មាត្រា៣ចែងកំណត់អំពីគោលដៅ គោលបំណង និងវិសាលភាព ។

ជំពូកទី២ ស្តីពីការរៀបចំសមាជ មាន៦មាត្រា ហើយពីមាត្រ៤ ដល់មាត្រា៩បានចែងអំពីប្រធានសមាជទីកន្លែង ប្រារព្ធសមាជ គណៈកម្មាធិការសមាជ មុខងារប្រធានសមាជ អគ្គលេខាធិការដ្ឋានសមាជ និងសមត្ថកិច្ចទទួលបន្ទុក ចំណាយថវិការសម្រាប់ដំណើរការសមាជ ។

ជំពូកទី៣ ស្តីពីការប្រព្រឹត្តទៅនៃសមាជ មាន៤មាត្រា ហើយពីមាត្រា១០ ដល់មាត្រា១៣ ចែងកំណត់ អំពីឥស្សរជន ដែលមានសមត្ថកិច្ចផ្តួចផ្តើមឱ្យមានប្រជុំសមាជ និងកោះអញ្ជើញចូលរួមប្រជុំសមាជ កូរ៉ុមប្រជុំ សំលេងអនុម័ត និង សេចក្តីសំរេចរបស់សមាជ ។

ជំពូកទី៤ ស្តីពីអន្តរប្បញ្ញត្តិ មាន១មាត្រា គឺមាត្រា១៤ បានចែងកំណត់អំពីរយៈពេលដំណើរការ និងរបៀបវារៈប្រជុំសមាជលើកដំបូង ។

### ៣-គោលបំណងនៃសេចក្តីព្រាងច្បាប់

សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មានគោលដៅកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា។

ការបង្កើតច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា គឺជាការធ្វើឱ្យមានប្រសិទ្ធភាពការងាររបស់ស្ថាប័ននីតិប្បញ្ញត្តិ ឱ្យមានការទទួលខុសត្រូវកាន់តែខ្ពស់ថែមទៀត ក្នុងការបម្រើប្រទេសជាតិ និងប្រជាជនតាមរយៈការឆ្លើយតប និងដោះស្រាយជាបន្ទាន់នូវរាលបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ និងប្រជាជាតិខ្មែរទាំងមូល ក្នុងនាមជាអ្នកតំណាងភូមិភាគ ព្រមទាំងការចូលរួមចំណែកក្នុងការដឹកនាំប្រទេសជាតិជាមួយរាជរដ្ឋាភិបាល។

### ៤-ខ្លឹមសាររួមនៃសេចក្តីព្រាងច្បាប់

សមាជរដ្ឋសភា និងព្រឹទ្ធសភាគឺជាការប្រជុំរួមគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ក្នុងកាលៈទេសៈដែលមានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ឯករាជ្យ បូរណភាពទឹកដី និងក្នុងពេលដែលប្រទេសជាតិទទួលរងនូវវិនាសកម្ម ឬប្រឈមនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរដែលចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ ។ ការប្រជុំរួមគ្នាជាសមាជ អាចដំណើការបាន ចាំបាច់ត្រូវមានច្បាប់ ដែលជាឧបករណ៍គតិយុត្ត សម្រាប់កំណត់អំពីយន្តការ នីតិវិធី និងវិធានផ្សេងៗ ដើម្បីធានាដល់កិច្ចដំណើរការ ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គសមាជនេះ ។

សេចក្តីព្រាងនេះ ធ្វើឡើងស្របទៅតាមបរិបទសង្គម និងផ្អែកទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងជាការធ្វើឱ្យមានប្រសិទ្ធភាពការងាររបស់ស្ថាប័ននីតិប្បញ្ញត្តិ ឱ្យមានការទទួលខុសត្រូវកាន់តែខ្ពស់ថែមទៀត ក្នុងការបម្រើប្រទេសជាតិ និងប្រជាជន តាមរយៈការឆ្លើយតប និងដោះស្រាយទាន់ពេលវេលានូវបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។ ដូចនេះសេចក្តីព្រាងច្បាប់នេះ ធ្វើឡើងស្របតាមគតិច្បាប់ដែលចែងជាសំអាង និងដោយធ្វើការសិក្សា វិភាគ ស្រាវជ្រាវ ជាលក្ខណៈជាតិ និងអន្តរជាតិ លើបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

## II-ការប្រជុំពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់របស់រដ្ឋសភា

- កិច្ចប្រជុំពិនិត្យអនុម័តច្បាប់របស់រដ្ឋសភា បានប្រព្រឹត្តទៅ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១០
- សម័យប្រជុំលើកទី ៥ នីតិកាលទី ៤ របៀបវារៈទី១២
- ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា
- អ្នកការពារសេចក្តីព្រាងច្បាប់ **ឯកឧត្តម ស៊ិក ប៊ុនហុក** តំណាងក្រុមហត្ថលេខី និងជាអ្នកតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាហត្ថលេខី ។

### ក-ការអនុម័តរបស់រដ្ឋសភាលើសេចក្តីព្រាងច្បាប់មួយជំពូកម្តង

+សំលេងអនុម័តយល់ព្រមលើរបៀបវារៈទី១២ សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជ

រដ្ឋសភា និងព្រឹទ្ធសភា យកមកពិនិត្យ ពិភាក្សា និងអនុម័ត មានសំលេងគាំទ្រ ៩៣ លើ ៩៨ សំលេង ។

- ការអនុម័តយល់ព្រមលើជំពូកទី១ សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មានសំលេងគាំទ្រ ៨០ លើ ៩៦សំលេង ។

- ការអនុម័តយល់ព្រមលើជំពូកទី២ សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មានសំលេងគាំទ្រ ៨៥ លើ ៩៦សំលេង ។

- ការអនុម័តយល់ព្រមលើជំពូកទី៣ សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មានសំលេងគាំទ្រ ៧៦ លើ ៩៦សំលេង ។

- ការអនុម័តយល់ព្រមលើជំពូកទី៤ សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មានសំលេងគាំទ្រ ៧៦ លើ ៩៦សំលេង ។

**+ ការអនុម័តយល់ព្រមលើខ្លឹមសាររួម សេចក្តីស្នើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា មានសំលេងគាំទ្រ ៧៧ លើ ៩៦ សំលេង ។**

**ខ-មតិយោបល់ពិភាក្សារបស់តំណាងរាស្ត្រ**

- ស្នើសុំបន្ថែមនូវចំនុចមួយចំនួនចូលទៅក្នុងមាត្រា៣
  - ករណីការប្រព្រឹត្តខុសរបស់តុលាការ
  - គោលការណ៍ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស
  - ករណីអភិបាលកិច្ចល្អ ( ករណីសមាជមើលឃើញថា ជាការប្រព្រឹត្តខុស ឬមានបញ្ហាពុករលួយកើតមាន )
  - បញ្ហាសេដ្ឋកិច្ច ( តើមានកញ្ចប់ថវិកាបំរុងទុកដែរ ឬទេនៅពេលប្រទេសជួបបញ្ហាប្រឈមនោះ )
- នៅក្នុងមាត្រា១០ ស្តីអំពីឥស្សរជនដែលមានសិទ្ធស្នើកោះប្រជុំសមាជនោះ តើយើងលើកអង្គព្រះមហាក្សត្រ ស្របរដ្ឋធម្មនុញ្ញដែរ ឬ ទេ ? ដែលអង្គព្រះមហាក្សត្រទ្រង់គ្រងរាជតែមិនកាន់អំណាចនោះ ។

**គ-មតិយោបល់ឆ្លើយតបរបស់តំណាងក្រុមហត្ថលេខី**

- ចំពោះបញ្ហាទាំងអស់ដែលបានលើកឡើងនេះ គឺយើងផ្អែកលើការវិភាគគ្រប់ជ្រុងជ្រោយព្រោះយើងនិយាយតែបញ្ហាសំខាន់ៗ ដែលអាចធ្វើឱ្យមានវិនាសកម្មដល់ប្រទេសជាតិតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀតនៅក្នុងត្រង់ទី៣បានទុកលទ្ធភាពឱ្យគណៈកម្មាធិការ ដែលមើលទៅឃើញថាបញ្ហាដែលកើតឡើង ជាបញ្ហាដែលធ្វើឱ្យមានមហន្តរាយដល់ជាតិ និងនៅក្នុងមាត្រា១០ ក៏បានទុកឱ្យឥស្សរជនកំពូលទាំងអស់មានលទ្ធភាពស្នើឱ្យមានការប្រជុំនេះផងដែរ ហើយចំពោះបញ្ហាដែលបានលើកទាំងប៉ុន្មានចំនុចខាងលើមកនេះគឺមានចែងនៅក្នុងច្បាប់ដាច់ដោយឡែករបស់គេរួចអស់ហើយ ។

- ចំពោះករណីអង្គព្រះមហាក្សត្រទ្រង់មានសិទ្ធិស្នើសុំអោយមានប្រជុំសមាជគឺយើងយោងទៅលើមាត្រា២២ថ្មី និងមាត្រា ២៤ថ្មី ដែលបានផ្តល់ព្រះរាជសិទ្ធិដល់អង្គព្រះមហាក្សត្រ ។

### III-ការវិភាគរបស់នាយកដ្ឋានស្រាវជ្រាវច្បាប់

នាយកដ្ឋានស្រាវជ្រាវច្បាប់ សូមចូលរួមនូវយោបល់មួយចំនួនជុំវិញបរិបទនៃបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធទៅលើ សេចក្តីស្នើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា រួមមាន :

**១-បទដ្ឋានគតិយុត្តពាក់ព័ន្ធ**

**ក-ធម្មនុញ្ញភាព**

សេចក្តីស្នើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់ :

- មាត្រា១១៦ថ្មី ចែងថា : *ក្នុងករណីចាំបាច់ រដ្ឋសភា និងព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។*
- មាត្រា១១៧ថ្មី ចែងថា : *បញ្ហាសំខាន់ៗរបស់ប្រទេសជាតិដូចមានចែងក្នុងមាត្រា១១៦ថ្មីខាងលើ ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។*

**ខ-បញ្ញត្តិពាក់ព័ន្ធក្នុងការអនុវត្តជាមួយច្បាប់ជាតិ**

**២-និត្យានុកូលភាព**

សេចក្តីស្នើច្បាប់នេះមានលក្ខណៈស្របទៅតាមទម្រង់ និងគតិច្បាប់ ដែលមានចែកចេញជាជំពូក និងមាត្រាច្បាស់លាស់ ។

**៣-ការចូលជាធរមាននៃសេចក្តីព្រាងច្បាប់**

ស្របតាមមាត្រា៩៣ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា " ***ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល១០ថ្ងៃគត់ ក្រោយពីប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះ បានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ*** "

**៤-ចំណាប់អារម្មណ៍**

នៅក្នុងសេចក្តីស្នើច្បាប់នេះ គាក់តែងឡើងស្របទៅនឹងនិន្នាការនយោបាយ ។ ហើយម្យ៉ាងវិញទៀតវាក៏ដល់ពេលសមល្មមសំរាប់បង្កើតសេចក្តីស្នើច្បាប់នេះឡើង នៅពេលច្បាប់នេះចេញទៅគឺជាឧបករណ៍គតិយុត្តមួយទៀតសំរាប់ឱ្យរដ្ឋាភិបាលយកភាលសេចក្តីសម្រេចរបស់សមាជទៅអនុវត្តឱ្យមានប្រសិទ្ធភាព ដែលមានចែងនៅក្នុងមាត្រា៣នៃសេចក្តីស្នើច្បាប់នេះតែម្តង ។

**សេចក្តីសន្និដ្ឋាន**

ក្រោយពីបានពិនិត្យសិក្សា និងវិភាគ ដូចមានអត្ថាធិប្បាយខាងលើរួចមកនេះ នាយកដ្ឋានស្រាវជ្រាវច្បាប់យល់ឃើញថា ទាំងទិដ្ឋភាពច្បាប់ ទាំងទិដ្ឋភាពតម្លៃនៃអត្ថបទច្បាប់ស្តីពី សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

នៃសមាជរដ្ឋសភា និងព្រឹទ្ធសភា អាចទទួលយកបានសមស្របតាមកាលៈទេសៈក្នុងពេលបច្ចុប្បន្នដែលប្រទេសយើងកំពុងត្រូវការច្បាប់ ហើយច្បាប់នេះ គោរពតាមនីតិវិធីរដ្ឋបាល ស្របតាមគោលនយោបាយច្បាស់លាស់ ។ ហើយសេចក្តីស្នើច្បាប់នេះផងដែរក៏មានការចូលរួមចំណែកផ្តល់យោបល់ពីសំណាក់ អ្នកជំនាញបរទេស ទីប្រឹក្សា អ្នកជំនាញក្នុងស្រុក និងមានការសិក្សាពីប្រទេសដែលមានសភាពីរជាន់ ដូចព្រះរាជាណាចក្រកម្ពុជាយើងផងដែរ ។

*រាជធានីភ្នំពេញ,* ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០

**អ្នកធ្វើរបាយការណ៍**

**តុប សំភី**

បានឃើញ និង ឯកភាព

**ប្រធាននាយកដ្ឋានស្តីធិ**

**ឈាប គុជ**